ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ......២២៥.........ប្រក.កសក

# ប្រកាស

## ស្តីពី

## ទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពី ការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក. ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129 Fax: (855) 23 217 320

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់អំពីទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន ដើម្បីធានាបាននូវការអនុវត្តវិធានបសុពេទ្យ អនាម័យ សុវត្ថិភាពសាច់ និង ផលិតផលសត្វ ជាប្រយោជន៍ការពារសុខភាពសាធារណៈ និង បរិស្ថាន ។

**ប្រការ ២ :** ទីតាំងសម្រាប់សាងសង់សត្តឃាតដ្ឋាននៃប្រភេទសត្វនីមួយៗ ត្រូវកំណត់លក្ខខណ្ឌដូចខាងក្រោម ÷

-ត្រូវស្ថិតនៅលើទីតាំងមួយសមស្រប ឆ្ងាយពីទីប្រជុំជន ឬ កន្លែងប្រមូលផ្តុំលំនៅដ្ឋានប្រជាជន សាលារៀន មន្ទីរពេទ្យ វត្តអារាម ទីសាធារណៈ បឹង ស្ទឹង ទន្លេ ឬ ប្រភពទឹកនានា ដែលមនុស្ស និង សត្វប្រើប្រាស់ជាប្រក្រតី

-ត្រូវស្ថិតនៅក្នុងទីតាំងណា ដែលពុំដែលទទួលរងនូវទឹកជំនន់គ្រប់រដូវកាល

-ត្រូវមានផ្ទៃដី ទំហំយ៉ាងតិចស្មើនឹង ៣ដង (បីដង) នៃអគារសត្តឃាតដ្ឋាន

-ត្រូវមានប្រព័ន្ធគមនាគមន៍ល្អគ្រប់រដូវកាល ងាយស្រួលក្នុងការបម្រើសកម្មភាពដឹកជញ្ជូនចេញ ចូលសត្វ សាច់ និង ផលិតផលសត្វ

-ត្រូវមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់

-ត្រូវមានប្រព័ន្ធអគ្គីសនី សម្រាប់ប្រើប្រាស់គ្រប់គ្រាន់ និង តាមលក្ខណៈបច្ចេកទេស នៅពេលកំពុងដំណើរការក្នុងសត្តឃាតដ្ឋាន ។

**ប្រការ ៣ :** បរិវេណសត្តឃាតដ្ឋានត្រូវរៀបចំកន្លែងសំខាន់ៗដូចខាងក្រោម ÷

ក.ត្រូវធ្វើរបងអំពីស៊ីម៉ងត៍ព័ទ្ធជុំវិញបរិវេណសត្តឃាតដ្ឋានកំពស់យ៉ាងតិច០៣(បី)ម៉ែត្រ និង ត្រូវមានប្រព័ន្ធលូបង្ហូរទឹកកខ្វក់ កាកសំណល់ចូលក្នុងឡជីវឧស្ម័ន ឬ អាងស្តុកធ្វើប្រព្រឹត្តិកម្ម ។

ខ. កន្លែងសម្រាប់មន្ត្រីបសុពេទ្យមានសមត្ថកិច្ច : បន្ទប់រដ្ឋបាល បន្ទប់យាម និង បន្ទប់ពិសោធន៍ ។

គ. កន្លែងសម្រាប់ម្ចាស់សត្តឃាតដ្ឋាន : បន្ទប់រដ្ឋបាល និង បន្ទប់សម្រាក ។

ឃ. កន្លែងសម្រាប់កម្មករស្នាក់នៅ ។

ង. កន្លែងបង្ខាំងសត្វ: សម្រាប់ដាក់សត្វសម្រាកដើម្បីពិនិត្យសុខភាពមុនពិឃាត និង សម្រាប់ដាក់សត្វឈឺ ឬ សត្វដែលសង្ស័យថាមានជំងឺ ។

ច. កន្លែងសម្រាប់ជីវសុវត្ថិភាព : បន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់មុនចូលកន្លែងធ្វើការ បន្ទប់លាងសម្អាតដៃជើង មុន និង ក្រោយចេញ-ចូលកន្លែងធ្វើការ និង បន្ទប់ឆ្លងកាត់ការសម្លាប់មេរោគមុនចូលធ្វើការ ។

ឆ. អគារសម្រាប់ពិឃាតសត្វ : ត្រូវរៀបចំជាផ្នែកដូចខាងក្រោម ÷

១. ផ្នែកពិឃាត

- កន្លែងបាញ់ទឹកសម្អាតសត្វ
- កន្លែងធ្វើឱ្យសត្វសន្លប់
- កន្លែងចាក់ក បង្ហូរឈាម
- កន្លែងស្រុសទឹកក្តៅ កោសរោម ដុតរោម និងពន្លាត់ស្បែក (សម្រាប់គោ ក្របី)
- កន្លែងវះពោះបារយកគ្រឿងក្នុងចេញ
- កន្លែងកាត់បំបែក បង់លេខ ឬកិបលេខ នៅលើផ្ទាំងសាច់ និង ផលិតផលសត្វ នីមួយៗ ជៀសវាងការច្រឡំគ្នា
- កន្លែងបាញ់ទឹកលាងសម្អាតផ្ទាំងសាច់ និង ផលិតផលសត្វ ។

នៅក្នុងផ្នែកនេះបន្ទាប់ពីការពិឃាតរួច សត្វត្រូវព្យួរជើងឡើងលើ ទំលាក់ក្បាលចុះមកក្រោម ឱ្យផុតពីផ្ទៃក្រាល និងត្រូវរត់តាមខ្សែរ៉កពីកន្លែងមួយ ទៅកន្លែងមួយទៀត ។

២. ផ្នែកត្រួតពិនិត្យសាច់ និងផលិតផលសត្វ

- កន្លែងព្យួរផ្ទាំងសាច់ និងផលិតផលសត្វ សម្រាប់មន្ត្រីបសុពេទ្យមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ និង បោះត្រា មុនធ្វើការនាំចេញពីសត្តឃាតដ្ឋាន
- កន្លែងពន្លះសាច់ ឬ កាត់សាច់ជាដុំៗ ។

ជ. កន្លែងសម្រាប់រក្សាទុកសាច់ និង ផលិតផលសត្វ :បន្ទប់ត្រជាក់សម្រាប់ថែរក្សាសាច់ និង ផលិតផលសត្វ និង បន្ទប់ត្រជាក់សម្រាប់ថែរក្សាសាច់ និង ផលិតផលសត្វ ដែលសង្ស័យថាមានមេរោគ ដើម្បីរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍ ។

ឈ. កន្លែងកំទេចសត្វ សាច់ និង ផលិតផលសត្វដែលមានមេរោគៈ កន្លែងសម្រាប់ពិឃាតសត្វឈឺ និង ឡសម្រាប់ដុតកំទេចចោលសត្វ សាច់ និង ផលិតផលសត្វ ។

ញ. កន្លែងសម្រាប់ទុកដាក់ផលិតផលសត្វ មិនអាចបរិភោគបានជាអាទិ៍ ឆ្អឹង រោម ស្បែក ស្នែង ក្រចក និង លាមក ។

**ប្រការ ៤ :** អគារពិឃាតសត្វ ត្រូវកំណត់ដូចខាងក្រោម ÷

ក. ត្រូវមានច្រកពីរដាច់ដោយឡែកពីគ្នា សម្រាប់បញ្ចូលសត្វរស់ និង សម្រាប់បញ្ចេញសាច់ និង ផលិតផលសត្វ ។

ខ. ដំណើរការពិឃាតសត្វ ត្រូវរៀបចំ និង កំណត់ដូចខាងក្រោម ÷

-ត្រូវអនុវត្តតាមគំនូសប្លង់មេ នៃដំណើរការពិឃាតសត្វដែលមានឧបសម្ព័ន្ធភ្ជាប់ក្នុងប្រកាសនេះ

- ដំណើរការពិឃាតសត្វ ត្រូវមានខ្សែសង្វាក់តាមលំដាប់លំដោយ ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ ។

គ. អគារពិឃាតសត្វ ÷

- ត្រូវរៀបចំអគារឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីធានាសុខភាពសាធារណៈ និង បរិស្ថាន
- ជញ្ជាំងត្រូវមានភាពរឹងមាំ ធន់សំណើម ធន់ការប៉ះទង្គិច មិនពុកផុយ ផ្ទៃរាបស្មើរលោង
- មុំនៃជ្រុងជញ្ជាំងត្រូវមានរាងកោង ងាយស្រួលដុសលាងសម្អាត និង សម្លាប់មេរោគ
- ផ្ទៃក្រាលត្រូវមានភាពរឹងមាំ មិនរអិល មិនជ្រាបនិងសារធាតុរាវ ធន់នឹងអាស៊ីត មានជម្រាលភ្ជាប់ទៅបណ្តាញលូ ងាយស្រួលលាងសម្អាត និង សម្លាប់មេរោគ
- ត្រូវមានពិតានរាបស្មើ ធន់សំណើម និង លាបថ្នាំពណ៌ភ្លឺរលោង
- ត្រូវបំពាក់ប្រព័ន្ធអគ្គិសនីឱ្យបានគ្រប់គ្រាន់ ទៅតាមលក្ខណៈបច្ចេកទេស
- ត្រូវបំពាក់ប្រព័ន្ធទឹកស្អាត ក្តៅ និង ត្រជាក់ ឱ្យបានគ្រប់គ្រាន់
- ត្រូវបំពាក់ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងដំណើរការពិឃាត ធ្វើអំពីលោហៈធាតុ ធន់នឹងអុកស៊ីតកម្ម សមស្របតាមលក្ខណៈបច្ចេកទេស ងាយស្រួលលាងសម្អាត និង សម្លាប់មេរោគ
- ត្រូវរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ ឱ្យសមស្របតាមលក្ខណៈបច្ចេកទេសធានាមិនឱ្យមានក្លិន និងការពារ សត្វចង្រៃមិនឱ្យចេញចូលបាន
- កន្លែងពន្លះសាច់ ឬ កាត់បំបែកសាច់ជាដុំៗ ត្រូវរៀបចំឱ្យផុតពីផ្ទៃក្រាល មានកំពស់យ៉ាងតិច ៨០ (ប៉ែតសិប) សង់ទីម៉ែត្រ ។ ផ្ទៃខាងលើដែលប៉ះផ្ទាល់នឹងសាច់ ឬផលិតផលសត្វ ត្រូវមានភាពរលោង ពុំមានប្រហោង ស្នាមរបើក ឬ ស្នាមប្រេះ ធន់នឹងសកម្មភាពនៃការកាប់បំបែកសាច់ ។

**ប្រការ ៥ :** សំណល់ឥតប្រយោជន៍គ្រប់ប្រភេទ ត្រូវតែបញ្ចេញចោលពីកន្លែងធ្វើការជាប្រចាំ ដោយត្រូវស្តុកទុកក្នុងអាងដែលមានគម្របអាចបិទបើកបាន និងប្រមូលចោលជាអចិន្ត្រៃយ៍ដើម្បីការពារកុំឱ្យមានក្លិន សត្វចង្រៃផ្សេងៗចេញ ចូលបាន ជៀសវាងមានការចម្លងមេរោគដល់សាច់ ផលិតផលសត្វ ទឹកស្អាត និង ឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត ។

បណ្តាញបំពង់បង្ហូរកាកសំណល់ និង បណ្តាញបញ្ចេញសំណល់រាវ រួមទាំងបណ្តាញលូទឹកកខ្វក់ ត្រូវមានចំនួនគ្រប់គ្រាន់ ដើម្បីធានាការបញ្ចេញទឹកកាកសំណល់ ។ ទឹកកខ្វក់ទាំងឡាយ ត្រូវតែបញ្ចូលទៅក្នុងអាងប្រព្រឹត្តិកម្ម ឬ ឡជីវឧស្ម័ន មុននឹងបញ្ចេញចោល ។

**ប្រការ ៦ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុពេទ្យបាល គ្រប់ប្រធានអង្គភាពដែលមានការពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម និង ប្រធានការិយាល័យផលិតកម្ម និង បសុពេទ្យបាល ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារៈកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៣...ខែ...មិថុនា....ឆ្នាំ ២០០៨

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ